**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:..៤៣..អនក្រ.បក**

# អនុក្រឹត្យ
# ស្ដីពី
# ការទទួលស្គាល់ សាកលវិទ្យាល័យ សៅស៊ីសថ៍អេសៀ

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ. ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្ដីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្ដមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្ដីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញយោបល់របស់ក្រសួងអប់រំ យុវជន និងកីឡា តាមលិខិតលេខ ១៨៧២ អយក.ឧស ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៦

## ស ម្រេ ច

មាត្រា ១ : ទទួលស្គាល់គ្រឹះស្ថានឯកជនមួយ ដែលមានឈ្មោះថា សាកលវិទ្យាល័យ សៅស៍អ៊ីសថ៍អេយសៀ " University of Southeast Asia " ហៅកាត់ជាភាសាខ្មែរ "ស.ស.អ" និងហៅកាត់ជាភាសាអង់គ្លេស " USEA " ។ សាកលវិទ្យាល័យនេះ មានទីតាំងនៅ ផ្លូវលោកតាណើយ ភូមិវត្តបូណ៍ ឃុំសាលាកំរើក ស្រុកសៀមរាប ខេត្តសៀមរាប និងស្ថិតក្រោមការគ្រប់គ្រង របស់ក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ២ : សាកលវិទ្យាល័យ សៅស៍អ៊ីសថ៍អេយសៀ មានភារកិច្ច :

- បណ្តុះបណ្តាលអ្នកជំនាញឯកទេសឧត្តមសិក្សាគ្រប់កម្រិត ស្របតាមបេសកកម្មរបស់សាកលវិទ្យាល័យ ។
- បង្កើនសមត្ថភាពមុខជំនាញបច្ចេកទេសដល់គ្រូបង្រៀន សាស្ត្រាចារ្យ សម្រាប់សាកលវិទ្យាល័យ សៅស៍-អ៊ីសថ៍អេយសៀ ។
- រៀបចំកម្មវិធីសិក្សា ឱ្យស្របតាមតម្រូវការទីផ្សារការងារ ស្តង់ដារអន្តរជាតិ និងបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា ។
- សិក្សាស្រាវជ្រាវខ្លឹមសារនៃការសិក្សា វិធីសាស្ត្របង្រៀន និងចងក្រងឯកសារបច្ចេកទេស វិទ្យាសាស្ត្រ ជាភាសាជាតិ និងភាសាបរទេស ឱ្យបានសមស្របសម្រាប់ប្រើប្រាស់ ។
- រៀបចំ និងដំណើរការជ្រើសរើសនិស្សិតឱ្យចូលរៀន ប្រលងចេញ និងស្វ័យវាយតម្លៃលើការសិក្សា ឱ្យបាន ត្រឹមត្រូវ តាមគោលការណ៍ និងប្រកបដោយតម្លាភាព ។
- ធ្វើការស្រាវជ្រាវវិទ្យាសាស្ត្រ ក្នុងឯកទេសរបស់សាកលវិទ្យាល័យ ។
- កសាងផែនការអភិវឌ្ឍ សម្រាប់សាកលវិទ្យាល័យ សៅស៍អ៊ីសថ៍អេយសៀ ។
- គ្រប់គ្រងនិយោជិត កម្មករ និស្សិត សាស្ត្រាចារ្យ និងទ្រព្យសម្បត្តិរបស់សាកលវិទ្យាល័យ សៅស៍អ៊ីសថ៍-អេយសៀ។
- ធ្វើសហប្រតិបត្តិការជាមួយអង្គការជាតិ-អន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល និងស្ថាប័ននានា ក្នុងគោល-បំណងធ្វើឱ្យកាន់តែល្អប្រសើរឡើង នូវការសិក្សា ការបង្រៀន និងការស្រាវជ្រាវ ។

មាត្រា ៣ : សាកលវិទ្យាល័យ សៅស៍អ៊ីសថ៍អេយសៀ ធ្វើការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ និងបរិ-ញ្ញាបត្រជាន់ខ្ពស់ ដោយមានមហាវិទ្យាល័យចំនួន ៦ :

១. មហាវិទ្យាល័យសិល្បៈ មនុស្សសាស្ត្រ និងអប់រំ

២. មហាវិទ្យាល័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

៣. មហាវិទ្យាល័យវិទ្យាសាស្ត្រសង្គម និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

៤. មហាវិទ្យាល័យពាណិជ្ជកម្ម និងទេសចរណ៍

៥. មហាវិទ្យាល័យកសិកម្ម និងអភិវឌ្ឍន៍ជនបទ

៦. មហាវិទ្យាល័យភាសាបរទេស

ទៅអនាគត សាកលវិទ្យាល័យសៅស៍អ៊ីសថ៍អេយសៀ អាចបើកសាខា ឬមហាវិទ្យាល័យ ឬមុខជំនាញ ឬប្រភេទបណ្តុះបណ្តាលផ្សេងទៀត ដោយរៀបចំសំណុំបែបបទ សុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៤ :** សាកលវិទ្យាល័យសៅស៍អ៊ីសថ៍អេយសៀ មានក្រុមប្រឹក្សាភិបាលមួយ ដើម្បីពិនិត្យ និងសម្រេចលើគោល-នយោបាយ ផែនការអភិវឌ្ឍ កម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធផ្សេងទៀត ។

**មាត្រា ៥ :** តួនាទី ភារកិច្ច និងវចនាសម្ព័ន្ធចាត់តាំងជាក់ស្តែង នៃសាកលវិទ្យាល័យសៅស៍អ៊ីសថ៍អេយសៀ ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាលនៃសាកលវិទ្យាល័យនេះ និងដោយមានការឯកភាពពីក្រសួងអប់រំ យុវជននិងកីឡា។

**មាត្រា ៦ :** សាកលវិទ្យាល័យសៅស៍អ៊ីសថ៍អេយសៀ ត្រូវគ្រប់គ្រងដោយសាកលវិទ្យាធិការមួយរូបដែលមានការទទួល-ស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៧ :** សាកលវិទ្យាធិការ មានភារកិច្ច :

- ទទួលខុសត្រូវចំពោះមុខច្បាប់ ក្នុងការគ្រប់គ្រងសាកលវិទ្យាល័យ សៅស៍អ៊ីសថ៍អេយសៀ ។
- រៀបចំផែនការយុទ្ធសាស្ត្រ សម្រាប់អភិវឌ្ឍសាកលវិទ្យាល័យសៅស៍អ៊ីសថ៍អេយសៀ ។
- ទទួលបន្ទុកអនុវត្តបទដ្ឋានទាំងឡាយ របស់រាជរដ្ឋាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា ដែលពាក់ព័ន្ធទៅនឹងការងារបណ្តុះបណ្តាល ។
- ធ្វើរបាយការណ៍គ្រប់គ្រង ប្រចាំឆមាស ប្រចាំឆ្នាំ និងសកម្មភាពផ្សេងៗទៀត ជូនក្រសួងអប់រំ យុវជន និងកីឡា តាមការកំណត់ ។
- កំណត់ការរៀបចំវចនាសម្ព័ន្ធ និងភារកិច្ច ដល់អង្គភាពនានាក្រោមឱវាទ ។
- បំពេញតួនាទី តាមឋានានុក្រម ចំពោះបុគ្គលិកទាំងអស់ របស់សាកលវិទ្យាល័យសៅស៍អ៊ីសថ៍អេយសៀ និងគោរពតាមវិធាន ស្តីពីការគ្រប់គ្រងបុគ្គលិក ។
- កំណត់បទបញ្ជាផ្ទៃក្នុង នៃសាកលវិទ្យាល័យសៅស៍អ៊ីសថ៍អេយសៀ ។
- ត្រូវធានាឱ្យមានសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម
- ជាតំណាងរបស់សាកលវិទ្យាល័យក្នុងការទំនាក់ទំនងជាមួយតតិយជន ។

**មាត្រា ៨ :** និស្សិតដែលបានរៀនចប់កម្មវិធីសិក្សា របស់សាកលវិទ្យាល័យសៅស៍អ៊ីសថ៍អេយសៀ និងទទួលបានជោគ-ជ័យ ក្នុងការប្រលងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាបត្រតាមកម្រិត និងតាមឯកទេសដែលបានសិក្សា ។ សញ្ញាបត្រនេះ ផ្តល់ឱ្យដោយសាកលវិទ្យាល័យសៅស៍អ៊ីសថ៍អេយសៀ ហើយមានការទទួលស្គាល់ ពីក្រសួង

អប់រំ យុវជន និងកីឡា ក្នុងករណីសាកលវិទ្យាល័យនេះ បំពេញ និងអនុវត្តតាមគោលការណ៍ និងបទដ្ឋាន របស់ក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៩** : បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១០** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ស្ថាប័នពាក់ព័ន្ធ និង សាកលវិទ្យាល័យសៅស៍អ៊ីសថ៍អេសៀ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- សាលាខេត្តសៀមរាប
- ដូចមាត្រា ១០
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ